ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥៦៣

ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២

**សាលដីកា**

លេខ ២៦៧ "V"

ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម | [redacted] | ជាប្រធាន |
| ២-លោកជំទាវ | [redacted] | ជាចៅក្រម |
| ៣-ឯកឧត្តម | [redacted] | ជាចៅក្រម |
| ៤-ឯកឧត្តម | [redacted] | ជាចៅក្រមរបាយការណ៍ |
| ៥-លោកជំទាវ | [redacted] | ជាចៅក្រម |

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្ដឹងសាទុក្ខលេខ ៤២០ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ថាត និង ជនជាប់ចោទឈ្មោះ [redacted] នឿន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០០ "ក្រ.V.ច" ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២២ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

**ជនជាប់ចោទ (អ្នកប្ដឹងសាទុក្ខ)**

១.ឈ្មោះ [redacted] **ថាត** ភេទប្រុស អាយុ ៥៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរធ្វើចំការ ទីកន្លែងកំណើតភូមិក្រូចឆ្មា ឃុំក្រូចឆ្មា ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម មានទីលំនៅមុន [redacted] បឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣ នាក់ ទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣១៩ ត.ព្រ ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២២។



Scanned with CamScanner

២.ឈ្មោះ[redacted] នឿន ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិញើសលើ ឃុំតាសែន ស្រុកទ្រាំង ខេត្តតាកែវ មានទីលំនៅមុនពេល[redacted] ស្រុកកំរៀង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ [redacted]រ" ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូនចំនួន ០៣ នាក់ ទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣២០ ត.ព្រ ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៧ ។

**ជាប់ចោទពីបទ៖** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៧ ចំណុច ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានមេធាវី [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិ ។

**I-អំពីអង្គហេតុ**

កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៧ វេលាម៉ោង ១២ និង ៣០នាទី កម្លាំងប្រឆាំងគ្រឿងញៀនសហការជាមួយកម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការនគរបាលខេត្តបាត់ដំបង បានចុះប្រតិបត្តិការបង្ក្រាបករណីជួញដូរគ្រឿងញៀននៅចំណុចភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ដោយឃាត់ខ្លួនបានជនជាប់ចោទបានចំនួន ០២នាក់ មានឈ្មោះ[redacted]នឿន ភេទប្រុស និងឈ្មោះ[redacted]ថាត ភេទប្រុស ហើយបានដកហូតថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកកICE) ចំនួន ១០ថង់ធំ ទម្ងន់ ៩៧៦,៧០ ក្រាម និងយ៉ាម៉ាគ្រាប់ចំនួន ៤៨ ថង់ ក្នុងនោះមាន ៩៥៧២ គ្រាប់ ទម្ងន់ ៨៨៩,៦០ ក្រាម ពីជនជាប់ចោទទាំងពីរនាក់ ។ ថ្នាំញៀននេះជនជាប់ចោទឈ្មោ[redacted] ថាត បានទិញពីឈ្មោះ ណាក់ អ្នករត់ម៉ូតូឌុប ហើយយកមកលក់ឱ្យ ឈ្មោះ [redacted]នឿន តាមការកម្ម៉ង់ទិញ។

សាលាដំបូងខេត្តបាត់ដំបង បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ង" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១. ផ្តន្ទាទោសលើជនជាប់ចោទ៖

១.១ ឈ្មោះ[redacted]នឿន ភេទប្រុស ៤៥ឆ្នាំ

១.២ ឈ្មោះ [redacted] ថាត ភេទប្រុស ៥៣ឆ្នាំ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗរយៈពេល ២០ (ម្ភៃ) ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន និង ពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល បង់ចូលថវិការដ្ឋ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រព្រឹត្តនៅចំណុចភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៧ ចំណុចទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. វត្ថុតាងចាប់យករួមមាន៖

-ទូរស័ព្ទម៉ាកអិនធុចពិល ចំនួន ០១គ្រឿង រឹបអូសជាសម្បត្តិរដ្ឋ។



Scanned with CamScanner

-សារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានទម្ងន់សរុប ៣៨៨.៨៩ ក្រាម រឹបអូសបំផ្លាញចោល។

៣. សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] នឿន និងឈ្មោះ [redacted] ថាត និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ២១ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ថាត ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] នឿន ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១០០ "ក្រ.V.ច" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ក.ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ២១ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ថាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

ខ.ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] នឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ។

៣. បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ថាត និងឈ្មោះ [redacted] នឿន តាមនីតិវិធីច្បាប់។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤២០ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ថាត និងជនជាប់ចោទឈ្មោះ [redacted] នឿន ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០០ "ក្រ.V.ច" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានឡើងធ្វើសេចក្តីរាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា យោងតាមភស្តុតាងទាំងអស់នៅក្នុងសំណុំរឿងនេះបានបង្ហាញថា ការសម្រេចសេចក្តីរបស់សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ភ្នំពេញមានលក្ខណៈត្រឹមត្រូវហើយ ព្រោះការសម្រេចផ្អែកលើសំអាងហេតុដែលសមស្របតាមអង្គហេតុ និងអង្គច្បាប់



Scanned with CamScanner

ដូចមានបញ្ជាក់នៅក្នុងសាលដីកាស្រាប់របស់សាលាឧទ្ធរណ៍ ។ សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍សមស្រប តាមអង្គហេតុ និងបញ្ញត្តិច្បាប់មាត្រា ៤០ កថាខណ្ឌទី ៧ ចំណុច ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះតាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនរកឃើញរកឃើញមានសារធាតុមេតាហ្វេមីន មានទម្ងន់សរុប ចំនួន ៣៨៨,៨៩ក្រាម គឺវាស្ថិតក្នុងស្ថានទម្ងន់នៃបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ មូលហេតុក្នុងបណ្តឹងសាទុក្ខមិនសមស្របតាមគតិច្បាប់ និងមិនសមស្របជាមួយកំហុសព្រហ្មទណ្ឌដែលជនជាប់ចោទ បាន ប្រព្រឹត្តិជាក់ស្តែង និងភស្តុតាងដាក់បន្ទុកដែលសមត្ថកិច្ចរឹបអូសបាន។

តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចៈ

-បដិសេធបណ្តឹងសាទុក្ខលេខ ៤២០ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ថាត និងជនជាប់ចោទឈ្មោះ[redacted] នឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយ ខុសនឹងគតិច្បាប់ ។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០០ "ក្រ.V.ច" ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២២ របស់សាលា ឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

-ក្រឡាបញ្ជីបានអានសារណាការពារ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០២២ របស់ជនជាប់ចោទ [redacted] ថាត។

-ក្រឡាបញ្ជីបានអានសារណាការពារ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២២ របស់ជនជាប់ចោទ [redacted] នឿន។

+មេធាវី [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថាត និងឈ្មោះ [redacted] នឿន បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនបានដាក់សេចក្តីសន្និដ្ឋានការពាររួចរាល់ហើយ ខ្លួនសូមឆ្លើយតបនឹងសេចក្តីសន្និដ្ឋាន របស់ឯកឧត្តមតំណាងមហាអយ្យការ ទី១ ឯកឧត្តមតំណាងមហាអយ្យការបានស្នើសុំបដិសេធបណ្តឹងសាទុក្ខនេះ ដោយសារតែមានមូលហេតុគ្រប់គ្រាន់ ទី២ បើតាមសារណាគឺឈ្មោ[redacted]ថាត ជាអ្នកសម្របសម្រួលទេ ហើយបើគាត់ដឹងថាជាប់ទោសច្រើនឆ្នាំ ក៏គាត់មិនប្រព្រឹត្តដែរ ។ តាមការពិនិត្យមើលឯកសារក្នុងរឿងនេះ ខ្លួន យល់ថា រឿងនេះគឺមានការរៀបចំឈ្មុតឆាក ដែលមានផែនការតាមវិធានញុះញង់របស់អាជ្ញាធរឱ្យជនជាប់ចោទ លក់គ្រឿងញៀន ដោយបានណាត់គ្នានៅចំការ ហើយបានឃាត់ខ្លួននៅទីនោះតែម្តង។ គ្រឿងញៀននោះមានតម្លៃ រហូតដល់ទៅ ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក តែជនជាប់ចោទគ្មានលទ្ធភាពទិញដូរ ច្រើនបែបនេះទេ គាត់ លក់ឱ្យគេដើម្បីបានកំម៉ុយខ្សុង ប៉ុណ្ណោះ ក្នុង១គ្រាប់បានប្រហែល ៣ បាត ។ ហើយម្យ៉ាងទៀតពេលដកហូត គ្រឿងញៀននោះ គឺមិនមែននៅក្នុងដៃរបស់[redacted] នឿន ទេ គឺនៅឈ្មោះ ណាក់ តែពេលសមត្ថកិច្ចទៅដល់ឈ្មោះ ណាក់ បានគេចចេញទៅ ហើយបានអាជ្ញាធរចាប់បានឈ្មោះ[redacted]ថាត និងឈ្មោះ[redacted]នឿន ។ តុលាការបាន ប្រកាសថា ឈ្មោះ ណាក់ គ្មានសាវតាជាតិ សម្រេចលើកលែងចោទប្រកាន់លើឈ្មោះ ណាក់ ប៉ុន្តែជាក់ស្តែង ឈ្មោះ ណាក់ គឺជាមេក្លោង យន្តការច្បាប់ត្រូវតែមានយុត្តិធម៌ ។ តែអង្គហេតុនេះគួរតែជាការ សមត្ថកិច្ច ដូច្នេះ សំអាងហេតុរបស់សាលាឧទ្ធរណ៍មិនសមស្របទេ តាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ខ្លួនស្នើសុំឱ្យ តុលាការកំពូលទទួលបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ។ ជនជាប់ចោទមានវ័យចាស់ជរា ហើយគាត់ក៏បាន សារភាព ប៉ុន្តែគាត់មិនដឹងថាការសារភាពរបស់គាត់មានវិសាលភាពត្រឹមកម្រិតណា ដែលធ្វើឱ្យ[illegible]មាន



Scanned with CamScanner

ការផ្តន្ទាទោសរហូតដល់ ២០ (ម្ភៃ)ឆ្នាំ ។ បើតុលាការមិនអាចសម្រាលទោស ដោយផ្អែកតាមមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះទេ តុលាការគួរពិចារណាលើវិធានការព្យួរទោស ។ ហេតុនេះការផ្តន្ទាទោសនេះ អយុត្តិធម៌ណាស់លើជនជាប់ចោទទាំងពីរ ត្រូវដាក់ទោសពីទោសតិចទៅជាធ្ងន់ ព្រោះជនជាប់ចោទគ្រាន់តែជាអ្នកសមគំនិតប៉ុណ្ណោះ។

សំណូមពរ ស្នើសុំតុលាការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាការពាររបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១. យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤២០ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២២ របស់ជនជាប់ចោទ [redacted] ថាត និងជនជាប់ចោទ [redacted] នឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និង មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.យល់ឃើញថា តាមសារណាការការពារ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០២២ របស់ជនជាប់ចោទជាដើមបណ្តឹងសាទុក្ខ [redacted] ថាត និងសារណាការការពារ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២២ របស់ជនជាប់ចោទ [redacted] នឿន បានសុំឱ្យតុលាការកំពូលបន្ធូរបន្ថយទោស ដោយលើកមូលហេតុថា ខ្លួនបានដឹងអំពីកំហុសក្នុងការប្រព្រឹត្តបទល្មើស ហើយខ្លួនមិនបានដឹងថាការប្រព្រឹត្តនេះត្រូវជាប់ទោសដល់ទៅ ២០ ឆ្នាំ នោះទេ និងសូមឱ្យផ្តល់ស្ថានសម្រាលទោសដល់ខ្លួន ហើយមេធាវីការពារសិទ្ធិជនជាប់ចោទបានលើកឡើងអំពីកំហុសអង្គច្បាប់របស់តុលាការអង្គហេតុដែលផ្តន្ទាទោសជនជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តែតាមពិតជនជាប់ចោទទាំងពីរគ្រាន់តែជាជនសមគំនិតប៉ុណ្ណោះហើយជនល្មើសជាមេធំ ចាប់មិនបាន និងផ្អែកលើវ័យចាស់ជរារបស់ជនជាប់ចោទ នោះ តុលាការកំពូលពិនិត្យលើអំពើរបស់ជនជាប់ចោទទាំងពីរ មានភស្តុតាងជាចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរនៅគ្រប់ដំណាក់កាលនៃនីតិវិធី ដែលក្នុងនោះជនជាប់ចោទ [redacted] ថាត បានយកគ្រឿងញៀនទៅឱ្យជនជាប់ចោទ [redacted] នឿន ហើយនៅពេលជនជាប់ចោទលក់ថ្នាំញៀនទៅឱ្យអ្នកទិញ ត្រូវបានសមត្ថកិច្ចចាប់ឃាត់ និងដកហូតថ្នាំញៀនបានជាក់ស្តែង រួមទាំងកោសលវិច័យលេខ ១០១៦៨/១៧ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៧ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា សារធាតុញៀនដែលចាប់យកពីជនជាប់ចោទទាំងពីរ ជាប្រភេទ មេតំហ្វេតាមីន ស្ថិតក្នុងតារាងទី ២ ដែលសំណាកទី ១ មានសារធាតុសុទ្ធ ៣២,៣២% និងសំណាកទី ២ មានសារធាតុសុទ្ធ ៩,១០% នោះ ទម្ងន់នៃភាពសុទ្ធនៃសារធាតុញៀនសំណាកទី ១ និងសំណាកទី ២ សរុប ៣៥៨,៨៩ ក្រាម

ឃើញថា តុលាការអង្គហេតុ មិនមានកំហុសក្នុងការកំណត់ពិរុទ្ធភាពលើជនជាប់ចោទទាំងពីរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិកថាខណ្ឌទី ៧ ចំណុចទី ៤ នៃមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងការផ្តន្ទាទោសជនជាប់ចោទទាំងពីរក្នុងម្នាក់ៗ ដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ និងពិន័យជាប្រាក់ម្នាក់ៗ ៤០ លានរៀល ស្ថិតក្នុងអប្បបរមានៃទោសស្របច្បាប់តាមកថាខណ្ឌទី ៧ នៃមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលកំណត់ពី ២០ ឆ្នាំ ទៅ ៣០ ឆ្នាំ ឬ អស់មួយជីវិត និងពិន័យជាប្រាក់ពី ៤០ លានរៀល ទៅ ១០០ លានរៀល ហើយសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលអំពីភស្តុតាង និងប្តឹងសុំឱ្យតុលាការកំពូលតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ មានភាពត្រឹមត្រូវតាមច្បាប់ ។ ផ្ទុយទៅវិញ ការលើកឡើងរបស់មេធាវីដែលថា ជនជាប់ចោទទាំងពីរជាជនសមគំនិត ហើយទោសក៏ត្រូវអនុវត្តខុសគ្នាដែរ នោះ តុលាការកំពូលពិចារណាឃើញថា ជនជាប់ចោទទាំងពីរត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន និងចាប់យកគ្រឿងញៀនបាន នៅពេលជនជាប់ចោទកំពុងលក់ថ្នាំញៀនទៅឱ្យអ្នកទិញ នោះការប្រព្រឹត្តអំពើជួញដូររបស់ជនជាប់ចោទទាំងពីរក្នុងឋានៈជាសហចារី ឬ ជាជនដែលដល់ ដូចមានកំណត់និយមន័យនៃអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ចំពោះការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬ ដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន តាមកថាខណ្ឌទី ៣ មាត្រា ៤០ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប៉ុន្តែ មិនមែនជាជនសមគំនិតដូចការលើកឡើងរបស់មេធាវីដែលមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌកំណត់ត្រឹមតែជាអ្នកជួយសំរួលដោយការផ្តល់ជំនួយ ឬ ការឧបត្ថម្ភដល់បទឧក្រិដ្ឋ ឬបទមជ្ឈិម នោះទេ។ លើសពីនេះទៀត តុលាការកំពូលពិចារណាឃើញថា តុលាការកំពូលនាពេលនេះ មានសមត្ថកិច្ចធ្វើការត្រួតពិនិត្យតែលើបញ្ហាការអនុវត្តច្បាប់របស់តុលាការអង្គហេតុដែលបានធ្វើការវិនិច្ឆ័យសេចក្តីប៉ុណ្ណោះ ប៉ុន្តែ មិនមានសមត្ថកិច្ចសម្រេចអំពីការបន្ធូរបន្ថយទោសតាមការសុំរបស់ជនជាប់ចោទបានទេ ហើយទោះជាយ៉ាងនេះក្តីតុលាការកំពូលពិនិត្យឃើញថា ការអនុវត្តស្ថានសម្រាលទោសដែលមានកំណត់តាមបញ្ញត្តិមាត្រា ៩៣ មាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ មិនអាចយកមកអនុវត្តចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រា ៣៣ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មិនមានមូលហេតុដូចមានកំណត់តាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០០ "ក្រ.V.ច" ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះ

## សម្រេច

**១.បដិសេធ** បណ្តឹងសាទុក្ខលេខ ៤២០ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២២ របស់ជនជាប់ចោទ [redacted] ថាត និងជនជាប់ចោទ [redacted] នឿន ។

**២.តម្កល់** សាលដីកាព្រហ្មទណ្ឌ ១០០ "ក្រ.V.ច" ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ។



Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០២៣ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០២៣ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

**បានឃើញ**

ថ្ងៃពុធ ៦រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។**

ថ្ងៃពុធ ៦រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]